**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបង្កើតគណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ

********

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ /០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

បង្កើតគណៈកម្មាធិការជាតិ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ អនុសាសន៍ គោលនយោបាយ និងវិធានការពាក់ព័ន្ធទាំងឡាយ របស់គំរោងផ្លូវដែកសិង្ហបុរី–គុនមីញ។

## ជំពូកទី ២

## សមាសភាព គណៈកម្មាធិការជាតិ

**មាត្រា២.-**

គណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ មានសមាសភាពដូចតទៅ :

| | |
|---|---|
| -រដ្ឋលេខាធិការ ក្រសួងសាធារណការនិងដឹកជញ្ជូន | ប្រធាន |
| -រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| -រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| -ប្រធានអគ្គនាយក រាជាយស្ម័យយានកម្ពុជា | សមាជិកអចិន្ត្រៃយ៍ |
| -អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| -អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| -អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| -អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| -អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| -អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| -អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| -អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| -អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| -តំណាង គណៈកម្មាធិការព្រំដែន | សមាជិក |
| -អគ្គលេខាធិការរង អាជ្ញាធរកំចាត់មីនកម្ពុជា | សមាជិក |
| -អភិបាលខេត្តពាក់ព័ន្ធ | សមាជិក |

**មាត្រា៣.-**

គណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ មានក្រុមការងារបច្ចេកទេសមួយជាជំនួយការ ។ សមាសភាពក្រុមការងារមានដូចខាងក្រោម :

| | |
|---|---|
| -ប្រធានអគ្គនាយក រាជាយស្ម័យយានកម្ពុជា | ប្រធាន |
| -តំណាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| -តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| -ប្រធាននាយកដ្ឋាន គមនាគមន៍និងប្រៃសណីយ៍ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| -ប្រធាននាយកដ្ឋាន ផែនការ-ស្ថិតិ ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| -ប្រធាននាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ ក្រសួងផែនការ | សមាជិក |
| -តំណាង ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| -តំណាង ក្រសួងបរិស្ថាន | សមាជិក |
| -តំណាង ក្រសួងការពារជាតិ | សមាជិក |
| -តំណាង ក្រសួងមហាផ្ទៃ | សមាជិក |
| -នាយក ផ្លូវ ស្ពាន អាគារ រាជាយស្ម័យយានកម្ពុជា | សមាជិក |
| -អភិបាលស្រុកពាក់ព័ន្ធ | សមាជិក |

-នាយករងរដ្ឋបាលទទួលបន្ទុកការិយាល័យផែនការ-ស្ថិតិ រអេយក លេខាធិការអចិន្ត្រៃយ៍

## ជំពូកទី ៣
## តួនាទី និងភារកិច្ច

**មាត្រា៤.-**

គណៈកម្មាធិការជាតិមានភារកិច្ច :

-ដឹកនាំ គ្រប់គ្រង សំរបសំរួលការងារលើគ្រប់សកម្មភាពក្នុងគំរោងផ្លូវដែកសិង្ហបុរី-គុនមីញ

-លើកសំណើជូន រាជរដ្ឋាភិបាល ពិនិត្យ និងសំរេច លើសកម្មភាពអនុវត្តគំរោងស្តារ និងកសាងផ្លូវដែកកម្ពុជា មានជាអាទិ៍ :

-ដោះស្រាយហិរញ្ញប្បទានទាំងក្នុងប្រទេស និងក្រៅប្រទេស

-ដោះស្រាយផលប៉ះពាល់ដីធ្លី ផ្ទះសំបែងរបស់ប្រជាពលរដ្ឋ ក្នុងគំរោងសាងសង់

-ការដោះមីន និងអាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះ តាមបណ្តោយផ្លូវដែកដែលត្រូវស្តារ និងសាងសង់

-លើកគំរោងចាំនស្ថានតំលៃអនុវត្តកំណាត់ផ្លូវដែកទីមួយៗក្នុងទឹកដីកម្ពុជា

-ចូលរួមប្រជុំពិភាក្សាការងារជាមួយបណ្តាប្រទេសអាស៊ាន និងដៃគូរអភិវឌ្ឍន៍នានា លើការងារអនុវត្តន៍គំរោង ផ្លូវដែកសិង្ហបុរី-គុនមីញ

-ធ្វើរបាយការណ៍ស្តីពីសកម្មភាពនានា និងលទ្ធផលការងារក្នុងការអនុវត្តន៍គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ ជូនដល់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ និងដៃគូរអភិវឌ្ឍន៍នានា ។

**មាត្រា៥.-**

ក្រុមការងារបច្ចេកទេសមានភារកិច្ច :

-សិក្សាស្រាវជ្រាវបច្ចេកវិទ្យាដែលមានសារៈប្រយោជន៍ដល់ការអនុវត្តន៍គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ

-រៀបចំរាល់ឯកសារបច្ចេកទេសពាក់ព័ន្ធនឹងគំរោងដាក់ជូនគណៈកម្មាធិការជាតិដើម្បីពិនិត្យ និងសំរេច

-ចូលរួមការងារ និងសិក្សាស្រាវជ្រាវជាមួយក្រុមការងារបច្ចេកទេស នៃបណ្តាប្រទេសអាស៊ានទៅតាមតួនាទី និងភារកិច្ចរបស់ខ្លួន ។

-ចូលរួមផ្តល់យោបល់រាល់កិច្ចប្រជុំតាមការអញ្ជើញរបស់គណៈកម្មាធិការជាតិ

-ប្រមូលទិន្នន័យការងារ និងឯកសារបច្ចេកទេសនានា យកមកចងក្រងធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិ និងទុកជាឯកសារសំរាប់តាមដានការអនុវត្តន៍គំរោង ។

-ទទួលការងារផ្សេងទៀតដែលគណៈកម្មាធិការជាតិប្រគល់អោយ ។

## ជំពូកទី ៤
## ថវិកាសំរាប់អនុវត្តន៍គំរោង

**មាត្រា៦.-**

គណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ មានកញ្ចប់ថវិកាដោយឡែក ។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា៧.-**

គណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រាជាផ្លូវការរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងការទំនាក់ទំនងការងាររបស់ខ្លួន ។

ប្រធានគណៈកម្មាធិការជាតិ អាចអញ្ជើញតំណាងពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធមន្ត្រីជំនាញ ឬអ្នកបច្ចេកទេសដទៃទៀតមកចូលរួមប្រជុំតាមការចាំបាច់ ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ គណៈកម្មាធិការព្រំដែន អាជ្ញាធរកំចាត់មីនកម្ពុជា គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ពាក់ព័ន្ធត្រូវអនុវត្តតាម អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០០៥*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ដូចក្នុងមាត្រា ៩*
*-ឯកសារ-កាលប្បវត្តិ*